**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យា

**ស្តីពី**

**ការវិនិយោគដាំដំណាំកសិ-ឧស្សាហកម្ម និង ចិញ្ចឹមសត្វ**

**រវាង**

**អនុគណៈកម្មការវិនិយោគខេត្តកំពង់ធំ**

**និង**

**ក្រុមហ៊ុន(ខេមបូឌា)ហ្វាម័រ អ៊ិនវេសមេន**

**<u>កិច្ចសន្យានេះធ្វើឡើងរវាង</u> :**

**អនុគណៈកម្មការវិនិយោគខេត្តកំពង់ធំ** តំណាងដោយឯកឧត្តមអភិបាលខេត្តកំពង់ធំ មានអាស័យដ្ឋានលេខៈ ....ថេរវិថីស្ទឹងសែន និង ផ្លូវតេជោប៊ែន ទូរស័ព្ទលេខៈ (៨៥៥) ៦២ ៩៦១ ២៨២ មានគណនីលេខ : .......... ......... ........... .... ... .....នៅធនាគារជាតិ នៃកម្ពុជាហៅថា ភាគី "ក" ។

ជាមួយនឹង

ក្រុមហ៊ុន **(ខេមបូឌា)ហ្វាម័រ អ៊ិនវេសមេន** (CAMBODIA)FARMER INVESMENT Co., Ltd ) មានស្នាក់ការភូមិបឹងកុក ស្រុកកំពង់ចាម ខេត្តកំពង់ចាម ទូរស័ព្ទលេខ (៨៥៥)១២ ៨៣៨ ៥១៥ Fax: ០៤២ ៣៩៦ ៧១៨ ដែលតំណាង ដោយលោក ឃ-សុធី ជនជាតិខ្មែរ ឋានៈប្រធានក្រុមហ៊ុនមានគណនីលេខ 0500306000187ធនាគារកាណាឌីយ៉ា សាខា ខេត្តកំពង់ចាម ហៅថា ភាគី "ខ" ។

យោង : -ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និង ច្បាប់វិសោធន៍កម្មនៃច្បាប់វិនិយោគ នៃព្រះរាជាណាចក្រ កម្ពុជា

-ច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា

-តាមលិខិតលេខ ៤២៩/០៣៣កសក.នជ.ជក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៧ របស់ក្រសួងកសិកម្មរុក្ខា ប្រមាញ់ និងនេសាទ។

-តាមលិខិតលេខ ១៨១៥.ស.ជ.ណ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

-តាមលិខិតលេខ ៧២ សប្រទចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីសិទ្ធិប្រទានរបស់សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាប្រទានសិទ្ធិជូនឯកឧត្តម ណាំ ទុំ អភិបាលខេត្តនិងជាប្រធានអនុគណៈកម្មាធិការវិនិយោគ ខេត្តកំពង់ធំ

ភាគីទាំងពីរបានឯកភាពគ្នាលើប្រការទាំងឡាយ មានដូចខាងក្រោមនេះ :

**ប្រការ ១ : កម្មវត្ថុនៃកិច្ចសន្យា**

កិច្ចសន្យានេះគឺភាគី "ក" យល់ព្រមផ្តល់ដីសម្បទានដែលមានផ្ទៃក្រឡាសរុបចំនួនប្រាំបួនរយសាមសិបប្រាំ(៩៣៥)

ហិកតា ដែលមានទីតាំងឃុំក្រយាក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ ជូនទៅភាគី " ខ " កាន់កាប់ប្រើប្រាស់ធ្វើវិនិយោគ ដាំដំណាំកសិ-ឧស្សាហកម្ម និងចិញ្ចឹមសត្វ ។

១.១ ទីតាំង និងទំហំផ្ទៃដីខាងលើ ពីពេលនេះទៅ ហៅថា " ទីតាំង " បានបញ្ជាក់កាន់តែច្បាស់ដោយមាន ឯកសារនានាភ្ជាប់ជា ឧបសម្ព័ន្ធនៃកិច្ចសន្យា ដូចខាងក្រោមនេះ :

-របាយការណ៍ស្តីពី លទ្ធផលចុះកំណត់ព្រំប្រទល់ដី និងធ្វើអង្កេតបញ្ហាផ្សេងៗទៀត ក្នុងតំបន់ដីសម្បទានចំនួន ៤.២៣៥ ហិកតា របស់ក្រុមហ៊ុន ស៊ីវ ហ្គេកអ៊ិនវេសមេន.ហ្គោលដេន ហ្វាម៉ីងអ៊ិនវេសមេន . ហេង មាន អ៊ិនវេសមេន. អាន សុភីហ្វាម៉ីង(ខេមបូឌា) និងក្រុមហ៊ុន(ខេមបូឌា) ហ្វាម័រអ៊ិនវេសមេន ចុះថ្ងៃទី ០៣ ខែមករា ឆ្នាំ២០០៧ របស់ក្រុមការងារ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សហការជាមួយជំនាញ និងអាជ្ញាធរមូលដ្ឋាន ។

-គំនូសផែនទី និងបញ្ជីកូអរដោណេចង្អុលទីតាំងដីមួយ(១) កន្លែង ។

១.២ ប្លង់ក្បាលដី និងទំហំផ្ទៃដី ដែលជាទីតាំងដីសម្បទានខាងលើនេះ ភាគី " ខ " ត្រូវស្នើទៅក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ តាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីចុះបញ្ជី សមស្របតាម សារាចរលេខ ០៥ សរណន ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៥ និងអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងរយៈពេលបី (៣) ខែ ក្រោយពីថ្ងៃ ចុះហត្ថលេខា នៃកិច្ចសន្យានេះ ។ ការចំណាយផ្សេងៗ សម្រាប់ការចុះបញ្ជីនេះ ជាបន្ទុក របស់ភាគី " ខ " ។

## ប្រការ២ : អំពីថិរវេលា

២.១ កិច្ចសន្យានេះមានរយៈពេលចិតសិប (៧០)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខានៃកិច្ចសន្យានេះតទៅ ។ សិទ្ធិនៃការកាន់កាប់ដីសម្បទាននឹងត្រូវប្រគល់ជូនបន្ទាប់ពីកិច្ចសន្យានេះចូលជាធរមានទៅតាមច្បាប់ជាធរមាន ។ សេចក្តីជូនដំណឹង បញ្ចប់កិច្ចសន្យាត្រូវផ្តល់ដំណឹងជាមុនចំនួនមួយ (០១) ឆ្នាំ ឬ នៅក្នុងឆ្នាំចុងក្រោយនៃកិច្ចសន្យា ។

២.២ ភាគី "ខ" មានសិទ្ធិសុំជួលបន្តកិច្ចសន្យាបន្ទាប់ពីរយៈពេលចិតសិប (៧០)ឆ្នាំ។ រយៈពេលមួយ (០១)ឆ្នាំ មុនពេលផុតកំណត់កិច្ចសន្យា ភាគី " ខ " អាចសុំធ្វើវិនិយោគបន្តទៅទៀតហើយការបន្តអាចធ្វើឡើងទៅបានក្នុងករណីមានគោលការណ៍អនុញ្ញាត ពីរាជរដ្ឋាភិបាលកម្ពុជាតាមសំណើរបស់ភាគី " ក " ដោយយោលទៅតាមការអនុវត្តន៍កន្លងមករបស់ភាគី "ខ" និងដោយ មានការពិភាក្សាឯកភាពពីភាគី " ក " អំពីលក្ខខ័ណ្ឌសម្រាប់កិច្ចសន្យាថ្មី ។

## ប្រការ៣ : គោលដៅ និង កម្មវិធីប្រើប្រាស់

គោលដៅ និងកម្មវិធីប្រើប្រាស់ទីតាំងរបស់ភាគី " ខ " គឺការធ្វើផលិតកម្មអាជីវកម្ម ដោយផ្អែកតាមរបាយការណ៍បច្ចេកទេស-សេដ្ឋកិច្ច និងផែនការមេដែលក្រុមហ៊ុនត្រូវធ្វើដូចចំណុច ៧.៣ នៃមាត្រា ៧ ដែលក្នុងនោះមានគោលសំខាន់ៗដូចតទៅ :

៣.១ គោលដៅផលិតកម្ម-អាជីវកម្ម :

៣.១.១ ផលិតកម្មចំបង : ដាំដំណាំកសិ-ឧស្សាហកម្ម និងចិញ្ចឹមសត្វ

(CAMBODIA) FARMER INVESTMENT
Co.,Ltd

## ប្រការ១៨ : ការចាប់ផ្តើម និង បញ្ចប់កិច្ចសន្យា

កិច្ចសន្យានេះត្រូវបានចូលជាធរមានចាប់ពីថ្ងៃទី....០៧.... ខែ....កញ្ញា........ឆ្នាំ ២០០៧ ហើយត្រូវផុតកំណត់នៅថ្ងៃទី....០៧.. ខែ....កញ្ញា..ឆ្នាំ ២០៧៧ ។

ធ្វើនៅកំពង់ធំ.ថ្ងៃទី....០៧.......ខែ.កញ្ញា.ឆ្នាំ ២០០៧

**តំណាងភាគី "ខ"**

**ក្រុមហ៊ុន(ខេមបូឌា)ហ្វាម៉ែរ អ៊ិនវេសមេន**

(CAMBODIA) FARMER INVESTMENT Co.,Ltd

**ឡាយ-សុធី**

**តំណាងភាគី "ក"**

**ប្រធានអនុគណៈកម្មការវិនិយោគខេត្ត**

**ណាំ-ទុំ**

**<u>កន្លែងតំកល់ឯកសារ</u> :**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ
-ក្រសួងផែនការ
-ក្រសួងយុត្តិធម៌
-ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់
-ក្រសួងឧស្សាហ៍កម្ម រ៉ែ និង ថាមពល
-ក្រសួងបរិស្ថាន
-តុលាការខេត្ត
-សាលាខេត្តកំពង់ធំ
-ខណ្ឌរដ្ឋបាលព្រៃឈើ
-មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-មន្ទីរបរិស្ថានខេត្ត
-មន្ទីររៀបចំដែនដីនគរូបនីយកម្ម និង សំណង់
-មន្ទីរផែនការខេត្ត
-មន្ទីរឧស្សាហ៍កម្ម រ៉ែ និង ថាមពល
-មន្ទីរកសិកម្មខេត្ត កំពង់ធំ
-ភាគី "ក"
-ភាគី "ខ"
-កាលប្បវត្តិ-ឯកសារ

# ផែនទី ទីតាំងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហ្វាម៉ា ស្ថិតនៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ




សញ្ញាសំគាល់

- ចំណុចព្រំដី
- ព្រំប្រទល់ស្នើសុំ
- ផ្លូវទឹក
- ផ្លូវគោក
- ខ្សែរយៈកំពស់
- ព្រំប្រទល់ព្រៃរក្សាទុក

គំរបព្រៃឈើឆ្នាំ ២០០២

| | |
|---|---|
| ព្រៃស្រោង | ៧ ហ.ត |
| ព្រៃផ្សេង១ | ៩៣៧ ហ.ត |
| ដីពុំមានគំរបព្រៃ | ១ ហ.ត |
| **ផ្ទៃដីសរុប** | **៩៤៥ ហ.ត** |
| **ផ្ទៃដីនៅសល់** | **៩៣៨ ហ.ត** |

1(539709 1396509)
2(539733 1396456)
3(539866 1396351)
4(539892 1396192)
5(539998 1396075)
6(540008 1396067)




